ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាពការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែ មករា ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពី ពន្ធនាគារ | ១ |
| ២- | សេចក្តីព្រាងគោលនយោបាយរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជា | ៣ |
| ៣- | កិច្ចប្រជុំសាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី របបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះនៅតាមសហគមន៍ | ៤ |
| ៤- | កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី ការធានារ៉ាប់រង | ៥ |
| ៥- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១០ | ៦ |
| ៦- | សកម្មភាពដ៏ទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

# សេចក្តីព្រាងច្បាប់ស្តីពី ពន្ធនាគារ

កាលពីថ្ងៃទី៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពី ពន្ធនាគារ** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងមហាផ្ទៃ សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ដើម្បីពង្រឹងការអនុវត្តច្បាប់សម្រាប់ផ្តន្ទាទោសដល់ជនប្រព្រឹត្តបទល្មើសឱ្យមានប្រសិទ្ធភាព និងជួយកាត់បន្ថយកំណើននៃបទល្មើសនៅទូទាំងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតអនុក្រឹត្យលេខ១៧ អ.ន.ក្រ. ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ សេចក្តីប្រកាសរួម លេខ២៧៨ រ.ប ៩៣ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៣ របស់ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ ក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាល ប្រឆាំងនឹងការដាក់ខ្នោះ ឬដាក់ប្រវាក់ទណ្ឌិតក្នុងពន្ធនាគារ ឬជនជាប់ឃុំឃាំង នៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្ន ប្រកាសលេខ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការគ្រប់គ្រងពន្ធនាគារ សារាចររបស់ក្រសួងមហាផ្ទៃ លេខ



០០១ ស.រ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យពន្ធនាគារស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ។ ជាមួយគ្នានេះ ព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់នូវបទប្បញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោស ដែលទទួលបានការយល់ព្រមឱ្យប្រើប្រាស់ពីក្រុមប្រឹក្សាផ្នែកសេដ្ឋកិច្ច និងសង្គម (អង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចលេខ ៦៦៣C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និងសេចក្តីសម្រេច លេខ២០៦៧(LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧។

ដោយមើលឃើញពីភាពលំបាកក្នុងការគ្រប់គ្រងអ្នកទោសនៅក្នុងពន្ធនាគារ និងម្យ៉ាងទៀត ដោយព្រះរាជាណាចក្រកម្ពុជាមិនទាន់មានច្បាប់ស្តីពីពន្ធនាគារផងនោះ ទើបក្រសួងមហាផ្ទៃ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារនេះឡើង ដើម្បីកំណត់អំពីសមត្ថកិច្ចគ្រប់គ្រង និងរចនាសម្ពន្ធ័ពន្ធនាគារ ការឃុំឃាំងអ្នកទោស សិទ្ធិ និងលក្ខខណ្ឌរស់នៅ



របស់ជនជាប់ឃុំ ការគ្រប់គ្រងពន្ធនាគារ ការបន្ធូរបន្ថយទោស និងលើកលែងទោស ការអប់រំ កែប្រែ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាទណ្ឌិត ឱ្យស្របតាមគោលការណ៍ជាអន្តរជាតិស្តីពីការគ្រប់គ្រងអ្នកទោស ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំមកក្នុងសង្គមវិញ និងទប់ស្កាត់ការការប្រព្រឹត្តបទល្មើសសាជាថ្មី។ សកម្មភាពទាំងអស់នេះ ត្រូវបានរៀបចំក្នុងគោលបំណងធានាឱ្យការគ្រប់គ្រងជនជាប់ឃុំទទួលបានសន្តិសុខ សុវត្ថិភាព សុខភាព និងមនុស្សធម៌(១)។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕



---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារ។

# សេចក្ដីព្រាងគោលនយោបាយរៀបចំទឹកដី នៃព្រះរាជាណាចក្រកម្ពុជា



កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:00នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ភាំង តុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ចុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្ដីព្រាងគោលនយោបាយរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី។

ដីនិងទឹក គឺជាធនធានធម្មជាតិដ៏សំខាន់ដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសម្រាប់ទ្រទ្រង់ជីវិត។ ដោយសារកំណើនប្រជាសាស្ត្រ កំណើននៃការប្រើប្រាស់ធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ គ្រប់ស្ថាប័នពាក់ព័ន្ធនឹងដីនិងទឹក ត្រូវមានយន្តការដឹកនាំ ការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងចីរភាព ពិសេសវិស័យកសិកម្ម ព្រៃឈើ ជលផល ធនធានទឹក រ៉ែ ទេសចរណ៍ ឧស្សាហកម្ម ការដឹកជញ្ជូន ការរៀបចំទីក្រុង ជនបទ និងសំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម។

ក្នុងបរិបទនៃសកលភាវូបនីយកម្ម ការរៀបចំទឹកដី ដែលជាផ្នែកចម្បងមួយនៃគោលនយោបាយដីធ្លី ត្រូវមានលក្ខណៈទន់ភ្លន់ និងតម្រង់ទិសគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ឱ្យមានប្រសិទ្ធភាពនិងចីរភាព។ នេះជាប្រការដ៏សំខាន់ចំពោះព្រះរាជាណាចក្រកម្ពុជា ដែលទើបទទួលបាននូវសុខសន្តិភាព ឯកភាពជាតិទឹកដី និងមានគោលដៅយុទ្ធសាស្ត្រដើម្បីបន្តពង្រឹងការបង្រួបបង្រួមសង្គមកម្ពុជាទាំងមូល ការធ្វើសមាហរណកម្មសេដ្ឋកិច្ចផ្ទៃក្នុង ការថែរក្សា និងពង្រឹងស្មារតីសាមគ្គីភាពស្រឡាញ់ទឹកដី ធនធានធម្មជាតិ វប្បធម៌ អរិយធម៌ជាតិ ដែលបានបាក់ស្រុតដោយសារសង្គ្រាមអូសបន្លាយអស់រយៈពេលរាប់ទសវត្ស។ ដូច្នេះ ការរៀបចំទឹកដី ត្រូវផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងសេចក្ដីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្ដីពីគោលនយោបាយដីធ្លី ព្រមទាំងតម្រង់ទិសទៅរកការអភិវឌ្ឍភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងប្រទេសទាំងមូល សំដៅពង្រឹងមូលធនសង្គម កសាងទំនាក់ទំនងក្នុងសង្គមឱ្យកាន់តែជិតស្និទ្ធ តាមរយៈការផ្ដល់សេវាកម្មផ្សេងៗខាង សេដ្ឋកិច្ច សង្គម ការកំសាន្ត ទេសចរណ៍។ល។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្ដីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះទាំងស្រុង៕

## កិច្ចប្រជុំសាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# របបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះនៅតាមសហគមន៍

កាលពីថ្ងៃទី១៨ និងថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆ្វារិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះ**នៅតាមសហគមន៍** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គ-លេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



គួររំឮកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបគោលនយោបាយ ចំពោះជនពិការនិងជនក្រីក្រងាយរងគ្រោះនៅតាមសហ-គមន៍ បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០។ អង្គប្រជុំនៅពេលនោះ បានពិភាក្សាល្អិតល្អន់លើវិសាលភាពអនុវត្ត ដែលនិយាយសំដៅដល់ជនពិការផង (ផ្អែកលើច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងដល់ជនក្រីក្រងាយរងគ្រោះផង ពុំមានច្បាប់ចង្អុលបង្ហាញទេ តែផ្អែកលើគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណ)។ អង្គប្រជុំបានស្នើសាមីក្រសួងរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះឡើងវិញ ដោយធ្វើយ៉ាងណាកំណត់ឲ្យសមស្រប សម្រាប់ការអនុវត្តជាក់ស្តែង។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងថ្មីនេះដោយយកចិត្តទុកដាក់។ ECOSOCC បានកត់សម្គាល់លើសេចក្តីព្រាងថ្មីនេះថា ចំណងជើងគួរទុកត្រឹមរបបគោលនយោបាយចំពោះជនពិការបានហើយ ដើម្បីកុំឱ្យវិសាលភាពធំពេក ហើយវាស្របតាមស្មារតីអង្គប្រជុំកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០។ ក៏ប៉ុន្តែក្រសួងសាមីសូមរក្សាទុកចំណងជើងដដែល ព្រោះក្រសួងអាចធ្វើការងារនេះបាន។ អង្គប្រជុំបានបន្តពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ឱ្យកាន់តែមានន័យពេញលេញ។

អង្គប្រជុំជំនាញបច្ចេកទេស បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ដោយទុកជូនកិច្ចប្រជុំអន្តរក្រសួងពិភាក្សាលើបញ្ហានេះបន្តទៀត។

## កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី
# ការធានារ៉ាប់រង

កាលពីថ្ងៃទី៥ ទី១១ ទី១៣ ទី១៨ ទី១៩ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) និង ឯកឧត្តម **ឡាំ ខា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ **សេចក្តីព្រាងច្បាប់ស្តីពី ការធានារ៉ាប់រង** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ  សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

អង្គប្រជុំជំនាញបច្ចេកទេស បានបន្តពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះយ៉ាងប្រុងប្រយ័ត្ន ហើយបានសម្រេចកែសម្រួលខ្លឹមសារ ទម្រង់ ពាក្យពេចន៍ និងឃ្លាប្រយោគ រហូតដល់មាត្រា៩១។ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារដែលមានសមាសភាព  ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងសាមី ដើម្បីជួយពិនិត្យ និងកែសម្រួលខ្លឹមសារបន្តនៃសេចក្តីព្រាងនេះ រួចយកដាក់ប្រជុំជំនាញបច្ចេកទេសនៅពេលក្រោយទៀត។




អង្គប្រជុំជំនាញបច្ចេកទេស បានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅមាត្រា៩១៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១០



កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានរៀបចំកិច្ចប្រជុំទូលាយមួយ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១០ ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

ទោះជាក្នុងឆ្នាំ ២០១០ សេដ្ឋកិច្ចពិភពលោកមានការប្រែប្រួលជាវិជ្ជមានខ្លះឡើងវិញពីវិបត្តិហិរញ្ញវត្ថុសកលលោក ក៏ជារួមនៅតែមិនទាន់មានស្ថេរភាពពេញលេញ និងបន្សល់ទុកនូវកត្តាអាក្រក់មួយចំនួនដែលជះឥទ្ធពលមកលើសេដ្ឋកិច្ច-សង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ វិបត្តិវិវាទព្រំដែនកម្ពុជា-ថៃ ក៏ជាសម្ពាធមួយថែមទៀតមកលើ ផលិតកម្មក្នុងស្រុក ថវិកាជាតិ ទេសចរណ៍ និងពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសយើង។ ផលិតកម្មកសិកម្ម កម្មន្តសាល ទេសចរណ៍ សំណង់ និងធុរកិច្ច គឺជាមូលដ្ឋានគ្រឹះសម្រាប់ទប់ទល់ជាមួយកត្តាមិនអំណោយផល និងសម្រាប់ការរីកចំរើនសេដ្ឋកិច្ច-សង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានបូកសរុប និងវិភាគលើសូចនាករ សេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ ប្រចាំឆ្នាំ២០១០ ដូចខាងក្រោម៖

## ១) ស្ថានភាពថ្លៃ

- អតិផរណានៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១០ មានអត្រាស្មើនឹង ៤% ដែលជាអត្រាសមរម្យ ស្ថិតក្នុងរង្វង់គោលនយោបាយគ្រប់គ្រងថ្លៃរបស់រាជរដ្ឋាភិបាល។ ចាប់តាំងពីឆ្នាំ២០០៤មក អតិផរណាឡើងដល់អត្រាខ្ពស់ជាប្រវត្តិសាស្ត្រ ២៥%[១] នៅឆ្នាំ២០០៨ និងទាបជាអវិជ្ជមាន –0.៧% នៅឆ្នាំ២០០៩។ រូបខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាអតិផរណានៃសេដ្ឋកិច្ចកម្ពុជា រយៈពេល ៧ឆ្នាំចុងក្រោយ។

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ត្រីមាសទី៤ ២០០៦ = ១០០%)




អត្រាអតិផរណា (២០០៤–២០១០)




[១] ធ្លាប់មានការប្រើប្រាស់ជាផ្លូវការនូវតួលេខ ១៩.៧% សម្រាប់អត្រាអតិផរណាឆ្នាំ ២០០៨ ដែលទទួលបានពីការគណនាសម្រាប់គ្រាគោលឆ្នាំ ២០០០។ ការងាកមកប្រើគ្រាគោល "ត្រីមាសទី៤ ឆ្នាំ២០០៦" ក្រសួងផែនការ បានកែតម្រូវអត្រាអតិផរណាតាមឆ្នាំផ្សេងៗទាំងអស់។

• ក្នុងអត្រាអតិផរណា ៤%នេះ ការរួមចំណែកសំខាន់ៗមាន៖ ក្រុមម្ហូបអាហារ ៤៧.២% ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត ១៦.៤% ការដឹកជញ្ជូន ២០.៨%ភោជនីយដ្ឋាន ៣.៣% និងទំនិញ និងសេវាកម្មផ្សេងទៀត ៦.០%។

• ទូរគមនាគមន៍ ជាក្រុមទំនិញតែមួយគត់ដែលមានការថយចុះថ្លៃចំនួន –២.៩%

• មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ឧស្ម័ន ៣០% ប្រេងសាំង ២២% ម៉ាស៊ូត ២០% ត្រីស្រស់ ១០% បន្លែ ៥.៩% និងទំនិញ និងសេវាកម្មផ្សេងទៀត ១០%។

• អង្ករជាមុខទំនិញយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជា ដែលមានការឡើងថ្លៃតែ ១.៨% ប៉ុណ្ណោះ

• បើពិនិត្យតាមក្រុមទំនិញនិមួយៗវិញ ការប្រៀបធៀបឆ្នាំ ២០១០/២០០៩ បង្ហាញបំរែបំរួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ល.រ | ក្រុមទំនិញ | បម្រែបម្រួលសន្ទស្សន៍ថ្លៃ | អត្រារួមចំណែក |
|---|---|---|---|
| 0 | ទំនិញប្រើប្រាស់គ្រប់មុខ (២៥៩ មុខ) | ៤% | ១00% |
| ១ | ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង ក្នុងនោះ ម្ហូបអាហារ | ៤.៣%<br>៤.៣% | ៤៨.0%<br>៤៧.២% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ២.៣% | 0.៩% |
| ៣ | សំលៀកបំពាក់ និងស្បែកជើង | ១.៩% | ១.៤% |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | ៣.៨% | ១៦.៤% |
| ៥ | គ្រឿងសង្ហារឹម និងសំភារៈប្រើប្រាស់ | ២.0% | ១.៤% |
| ៦ | សុខាភិបាល | ១.១% | ១.៤% |
| ៧ | ការដឹកជញ្ជូន | ៦.៨% | ២0.៨% |
| ៨ | **ទូរគមនាគមន៍** | –២.៩% | –0.៩% |
| ៩ | ការកំសាន្ត និងវប្បធម៌ | 0.៤% | 0.៣% |
| ១0 | ការសិក្សា | ២.៩% | 0.៨% |
| ១១ | ភោជនីយដ្ឋាន | ២.២% | ៣.៣% |
| ១២ | ទំនិញ និងសេវាកម្មផ្សេងទៀត | ១0.0% | ៦.0% |

• ជារួម អត្រាប្តូរប្រាក់ រ/ដុល្លារ មានស្ថេរភាពក្នុងកំលុងពេល១0ឆ្នាំចុងក្រោយនេះ។ ក្នុងចន្លោះឆ្នាំ ២00១-២0១0 អត្រាប្តូរប្រាក់រៀល/ដុល្លារ កើនឡើងជាមធ្យមប្រចាំឆ្នាំតែ 0.៩% ប៉ុណ្ណោះ។

• ដោយឡែកបើប្រៀបធៀបឆ្នាំ២0១0|២00៩ យើងសង្កេតឃើញថា៖

- ប្រាក់រៀលចុះថោក ១.0% ធៀបនឹងដុល្លារសហរដ្ឋអាមេរិក
- ប្រាក់រៀលចុះថោក ៩.៤% ធៀបនឹងបាតថៃ
- ប្រាក់រៀលឡើងថ្លៃ ៥.៩% ធៀបនឹងដុងវៀតណាម ដោយសាររដ្ឋាភិបាលវៀតណាមបានបញ្ចុះតម្លៃដុងវៀតណាម។

## ២) ស្ថានភាពថវិកាជាតិ

• យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២0១0នេះ សំរេចបានចំនួន ៦,0៣៦ ពាន់លានរៀល ស្មើនឹង ៩៩% នៃគំរោង ក្នុងនោះ ចំណូលមូលធន ២៩៦ ពាន់លានរៀល ស្មើនឹង ៧២% នៃគំរោង និងចំណូលចរន្ត ៥,៧៤0 ពាន់លានរៀល ស្មើនឹង ១0១% នៃគំរោង។

• បើធៀបនឹងឆ្នាំ ២00៩ ចំណូលថវិកាជាតិកើនឡើង ១៦% ដែលក្នុងនោះ ចំណូលចរន្តកើនឡើង ១៨% ប៉ុន្តែចំណូលមូលធនថយចុះ ១៤%។

▪ ការកើនឡើងនៃចំណូលចរន្ត បណ្តាលមកពីចំណូលសារពើពន្ធកើនឡើង ១៣% និងចំណូលមិនមែនសារពើពន្ធកើនឡើង ៤៩%។

| មុខចំណូល | អនុវត្ត គម្រោង | បម្រែបម្រួលធៀបនឹងឆ្នាំ២០០៩ | មុខចំណូល | អនុវត្ត គម្រោង | បម្រែបម្រួលធៀបនឹងឆ្នាំ២០០៩ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** | ៩៧% | +១៣% | **ចំណូលមិនមែនសារពើពន្ធ** | ១២៣% | +៤៩% |
| ✓**ពន្ធ និងអាករគយ** | ១១៣% | +១៧% | ✓នេសាទ | ៨៥% | +១៧% |
| – ពន្ធគយ (របបនាំចូល) | ១០៨% | +១៤% | ✓ រុក្ខាប្រមាញ់ | ១៤៣% | +៩២% |
| – អាករពិសេសលើរបបនាំចូល | ១១៥% | +២៥% | ✓ សម្បទានរ៉ែ | ១,៥៦១% | +១,២៦១% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១០៨% | +៨.៥% | ✓អាកាសចរណ៍ស៊ីវិល | ១០៧% | +០.៥% |
| –អាករនាំចេញ | ១០០% | +៤៩% | ✓ ផលទុនទេសចរណ៍ | ៨១% | +២៥% |
| –អាករបន្ថែមលើផលិតផលគេលសិលា | ១២០% | +២៣% | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៩៤% | –១០% |
| ✓ **ចំណូលពន្ធដារ** | ៩១% | +១៩% | ✓អាករស្ថានទូត លិខិតឆ្លងដែន និងទិដ្ឋាការ | ៩៨% | +១៧% |
| –ពន្ធលើប្រាក់បៀវត្ស | ៨០% | +១៩% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ១៤៣% | +១៨% |
| – ពន្ធលើប្រាក់ចំណេញ | ៨៤% | +៤% | ✓ ជួលរោងចក្រ សហគ្រាស | ៨៩% | +៨.២% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ៧៣% | +១៦% | ✓ឯកជនភាវូបនីយកម្ម | ៧២% | +២៦% |
| – អាករលើផលរបរ | ៥៩% | +៥៥% | ✓ ការលក់អចលនកម្ម | ៤,២៣៤% | +៣២២% |
| – អាករលើតម្លៃបន្ថែម | ៨៧% | +២២% | | | |
| –អាករពិសេសលើទំនិញមួយចំនួន | ១១៨% | +៣៩% | | | |
| –ផ្សេងៗ | ៦៨% | +៣២% | | | |
| –ពន្ធបរិការខេត្តក្រុង | ១៣៥% | +៣៦% | | | |
| ✓ **ចំណូលសារពើពន្ធផ្សេងៗ** | ១១៣% | –១.៥% | | | |
| –ចំណូលពីកាស៊ីណូ | ១០៨% | +២.៣% | | | |
| –ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ២៣៩% | +១៣% | | | |
| –ចំណូលពីកម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ១១០% | –១.៤% | | | |

• **ចំណាយថវិកាជាតិ**ក្នុងឆ្នាំ ២០១០ អនុវត្តបាន ៥,៩៥៦.១ ពាន់លានរៀល ស្មើនឹង ៧២% នៃគម្រោង ក្នុងនោះ ចំណាយចរន្ត ៤,៧៦៤ ពាន់លានរៀល ស្មើនឹង ៩៥% នៃគម្រោង និងចំណាយមូលធន ១,១៨៧ពាន់លានរៀលស្មើនឹង ៣៦% នៃគម្រោង។

• បើប្រៀបធៀបឆ្នាំ ២០១០/២០០៩ យើងសង្កេតឃើញថា៖

▪ ចំណាយថវិកាជាតិកើនឡើង ៧.៩%

▪ ចំណាយចរន្តកើនឡើង ៨.៣%

▪ ចំណាយមូលធនកើនឡើង ៥.៨%

• ជាលទ្ធផល **តុល្យភាពថវិកាជាតិ** នាឆ្នាំ២០១០ មានអតិរេកចំនួន ៨៩ពាន់លានរៀល។

## ៣) ស្ថានភាពរូបិយវត្ថុ

• សេដ្ឋកិច្ចដុល្លារូបនីយកម្មនៃកម្ពុជាក្នុងឆ្នាំ ២០១០ បង្ហាញសមាសធាតុរូបិយវត្ថុដូចខាងក្រោម៖

▪ រូបិយវត្ថុផ្សេងៗមាន ៨៣.៥% នៃរូបិយវត្ថុទូទៅ M2 (២០០៩ = ៨០.៨%) ក្នុងនោះ៖

– ប្រាក់បញ្ញើជារូបិយប័ណ្ណមាន ៨១.៤% នៃ M2 (២០០៩ = ៧៩%)

– ប្រាក់បញ្ញើមានកាលកំណត់និងសន្សំមាន ២.១% នៃ M2 ប៉ុណ្ណោះ (២០០៩ = ២.០%)។

- រូបិយវត្ថុ *M1* មាន ១៦.៥%នៃ *M2* (២០០៩ = ១៩.២%) ក្នុងនោះ៖
  – រូបិយវត្ថុក្រៅធនាគារមាន ១៥.៩% នៃ *M2* (២០០៩ = ១៨.៥%)
  – ប្រាក់បញ្ញើចរន្ត មាន ០.៦% (២០០៩ = ០.៧%)។

• ទោះជាសមាសធាតុ រូបិយវត្ថុមិនមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ក្តី ធៀបនឹងឆ្នាំមុន ជារួម រូបិយវត្ថុទូទៅ *M2* មានការកើនឡើងជាលំដាប់។ ក្នុងអំឡុងពេល ១០ឆ្នាំ ២០០១-២០១០ *M2* ជាមធ្យមកើនឡើង ២៨.៥%ប្រចាំឆ្នាំ ឯឆ្នាំ២០០៧ *M2* កើនឡើងក្នុងអត្រាខ្ពស់បំផុត ៦៣%។

• ក្នុងឆ្នាំ ២០១០ *M2* មានចំនួន ១៩,៤៧៧ពាន់លានរៀល កើនឡើង២០% បើធៀបនឹងឆ្នាំ២០០៩។ ការកើនឡើងនៃ *M2* នេះបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ៣.២% ប្រាក់បញ្ញើចរន្ត ៣.១% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ១៤% និងប្រាក់បញ្ញើជារូបិយប័ណ្ណ ២៤%។

• ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ នាឆ្នាំ២០១០ មានចំនួន ២,៥៤៨ លានដុល្លារ កើនឡើង ១៣% បើធៀបនឹងឆ្នាំ ២០០៩។

• ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ ជាទូទៅមានការកើនឡើង*** ដោយឡែកក្នុងឆ្នាំ ២០១០ មានចំនួន ៧,៣០៩ ពាន់លានរៀល កើនឡើង ២២% បើធៀបនឹងឆ្នាំ ២០០៩។

• ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ ក្នុងឆ្នាំ ២០១០ មានចំនួន ១៣,២២១ ពាន់លានរៀលបើធៀបនឹងឆ្នាំ ២០០៩ កើនឡើង ២៥%។

• ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានចំនួន ១,៧២៥ ពាន់លានរៀល កើនឡើង ៣៩% ។

• អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យមនៃធនាគារពាណិជ្ជទាំងអស់) ស្មើនឹង ៦.៥៩% កើនឡើង ១% ។

• អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជ ស្មើនឹង **៤.៤១%** ថយចុះ ១៧% ។

• អត្រាការប្រាក់កំចីប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ ស្មើនឹង ២២.៨៣% ថយចុះ ១.១% ។

• អត្រាការប្រាក់កំចីប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជ ស្មើនឹង ១៧.២១% កើនឡើង ៤.៧% ធៀបនឹងឆ្នាំ ២០០៩។

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

• យោងតាមទិន្នន័យ *ឆ្នាំ២០១០ និងការប្រៀបធៀប* ២០១០|២០០៩ បង្ហាញទិដ្ឋភាពដូចខាងក្រោម៖

- ***កសិកម្ម***
  - ផលិតផលស្រូវសរុបមានចំនួន ៨,០៧៦ ពាន់តោន កើនឡើង ៥៧ពាន់តោន ឬ ២.៤%
    ✓ នេះជាចំបងដោយសារការកើនឡើងនៃផ្ទៃដីដាំស្រូវ ពី ២,៣៣៤ពាន់ហិកតា មក ២,៣៩១ ពាន់ហិកតា
    ✓ ឯទិន្នផលវិញមានកំរិតជាមធ្យម ៣.៤តោន/ហិកតា កើនឡើង ០.២តោន/ហិកតា

**ទិន្នផលស្រូវនៅព្រះរាជាណាចក្រកម្ពុជា ២០០៥-២០១០ (តោន/ហិកតា)**



✓ផលិផលស្រូវក្នុងឆ្នាំនេះ មានអតិរេកចំនួន ៣,៧៤០ពាន់តោន

- ផលិតកម្មនេសាទសរុបមានចំនួន ៥៣៥ ពាន់តោន កើនឡើង ១.៥%

▪ *ឧស្សាហកម្ម*

- ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានតម្លៃ ៣,១២៦ លានដុល្លារ កើនឡើង ២១%។ ជាទូទៅ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងតែងតែមានកំណើនធំ នៅឆមាសទី២។

- ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២,២៣២.៤លានគីឡូវ៉ាត់ម៉ោង កើនឡើង ២២% ។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ៣០.៩ លានគីឡូវ៉ាត់ម៉ោង ថយចុះ ៣៤%។

- ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹក មានចំនួន ១២៨.៦លានម៣ កើនឡើង ១៥% ។

- រោងចក្រថ្មីដែលចុះបញ្ជីនៅក្រសួងឧស្សាហកម្ម មានចំនួន ៧៤ កើនឡើង ៦៨% ។

-ឧស្សាហកម្មធុនតូច និងសិប្បកម្មបើកថ្មីមានចំនួន ១១៤ ថយចុះ ១៤%

- ឧស្សាហកម្មធុនតូច និងសិប្បកម្មបន្តមានចំនួន ១៨១ ថយចុះ ៥៣%

- គម្រោងវិនិយោគ**អនុញ្ញាត**ដោយ គ.វ.ក./ក.អ.ក.[២] ក្នុងឆ្នាំ២០១០ មានចំនួន ១១៨ គម្រោង។ បើគិតជាទឹកប្រាក់ គម្រោងទាំងនេះមានតម្លៃស្មើនឹង ២,៩៤១ លានដុល្លារ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន ១៥៨ពាន់នាក់ ។

▪ *សំណង់*

-សំណង់អនុញ្ញាតអោយសាងសង់មានចំនួន ៣,២៨៧ពាន់ម២ ថយចុះ ៥០%។ បើគិតជាទឹកប្រាក់ ស្មើនឹង ៨៤០លានដុល្លារ ថយចុះ ៥៨%។

-សំណង់ដែលពេញនិយមមាន លំនៅឋាន (អនុញ្ញាត១,៤៧០ពាន់ម២ ស្មើនឹង ៤៥% នៃផ្ទៃក្រលាអនុញ្ញាតសរុប) និង ឧស្សាហកម្ម (អនុញ្ញាត៦១៥ពាន់ម២ ស្មើនឹង ១៩% នៃផ្ទៃក្រលាអនុញ្ញាតសរុប)។

▪ *សេវាកម្ម និងទេសចរណ៍*

- ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានចំនួន ១,៤៦២ កើនឡើង ២០%

- ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដា មានចំនួន ២,៥៩០ កើនឡើង ៦៣%

- ការដាក់ពាក្យរកការងារនៅក្រសួងការងារមានចំនួន៤១,៥៩៣នាក់ កើនឡើង ២២០%

- បានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុនមានចំនួន ៧២,១១៨នាក់ កើនឡើង ៧៧%

- ទំនិញឆ្លងកាត់តាមផ្លូវសមុទ្រ (សរុប៥ផែ) មានចំនួន ៣,៩២១ ពាន់តោន ថយចុះ ១៥%។ ក្នុងនោះ

✓ ទំនិញឆ្លងកាត់ផែកំពង់សោម មានចំនួន ២,១៥៥ ពាន់តោន កើនឡើង ១៦%

✓ ទំនិញឆ្លងកាត់ផែឧកញ៉ាម៉ុង មានចំនួន ២៣៤ ពាន់តោន កើនឡើង ៨.៣%

✓ ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុង មានចំនួន ២៥១ ពាន់តោន ថយចុះ ៨១% ដោយរាជរដ្ឋាភិបាលបិទការនាំខ្សាច់ចេញក្រៅ។

✓ ទំនិញឆ្លងកាត់ផែភ្នំពេញ មានចំនួន ១,២៥៣ ពាន់តោន កើនឡើង ៧.៨%

- អ្នកដំណើរតាមផ្លូវអាកាសក្នុងស្រុក មានចំនួន ១៣៦ពាន់នាក់ ថយចុះ ៥.៣%

- អ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិ មានចំនួន ៣,០៣៨ពាន់នាក់ កើនឡើង ១៩%

- ចំនួនអ្នកទេសចរសរុបមានចំនួន ២,៥០៨ ពាន់នាក់ កើនឡើង ១៦%

[២] ដោយសារមានភាពចម្រូងចម្រាស់ និងមិនទាន់មានការកែតម្រូវច្បាស់លាស់របស់ គ.វ.ក./ក.អ.ក. លើតួលេខទុនវិនិយោគឆ្នាំ២០០៩ ក.ស.វ.មិនមានការប្រៀបធៀបបម្រែបម្រួលនៃតួលេខក្នុងឆ្នាំ២០១០ទេ។



✓ អ្នកទេសចរតាមផ្លូវអាកាសមានចំនួន ១,៣០៤ ពាន់នាក់ កើនឡើង ១៧%

✓ អ្នកទេសចរតាមផ្លូវគោក និងទឹកមានចំនួន ១,១៥៨ ពាន់នាក់ កើនឡើង ២៤%

## ៥) ស្ថានភាពពាណិជ្ជកម្ម

• ជារួម កម្ពុជាមានឱនភាពជញ្ជីងពាណិជ្ជកម្មជាប្រចាំ ទោះបីការនាំចេញកន្លងមក មាននិន្នាការកើនឡើងក្តី។

• យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**ក្នុងឆ្នាំ ២០១០ មានចំនួន ២០,១៩៥ ពាន់លានរៀល កើនឡើង ២៩% បើធៀបនឹងឆ្នាំ ២០០៩។ ក្នុងនោះ៖

| មានការថយចុះ | មានការកើនឡើង |
|---|---|
| - ស៊ីម៉ង់ត៍ ៩.៩% | -ប្រេងឥន្ធនៈ ១៧% |
| - គ្រឿងអេឡិចត្រូនិច ១៧% | -ឧស្ម័ន ១៤% |
| - អង្ករ ២៣% | - អគ្គិសនីនាំចូល ៩៧% |
| - សំលៀកបំពាក់ ២.៧% | - ដែកសំណង់ ១៦% |
| - បារី ០.៥% | - រថយន្តសរុប (ជាសាច់ប្រាក់) ៤៥% |
| - ភេសជ្ជៈ ៤៦% | - ត្រាក់ទ័រនិងគោយន្ត ៥៨% |
| - ប្រេងឆា ៦៥% | - ម៉ូតូ ៦០% |
| - ប៊ីចេង ៤៦% | - ស្រូវសាលី ២០% |
| | - ផ្លែឈើនិងបន្លែ ៣១% |
| | -ជីនិងថ្នាំកសិកម្ម ១១% |
| | - ការនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ ២៤% |

• **ការនាំចេញ**ក្នុងឆ្នាំ ២០១០ មានចំនួន ១៥,៧៣៧ ពាន់លានរៀល កើនឡើង ២៩% បើធៀបនឹងឆ្នាំ ២០០៩។ ក្នុងនោះ៖

- ការកើនឡើងមាន ការនាំចេញផលិតផលឈើកែច្នៃ ៧០៩% ផលិតផលវាយនភណ្ឌនិងស្បែកជើង ២៥% និងអង្ករ ២២៥%
- ការថយចុះមាន ការនាំចេញផលិតផលនេសាទ ៤៩% និងកៅស៊ូ ១១% ។

• *ដូច្នេះ ក្នុងឆ្នាំ២០១០ ឱនភាពជញ្ជីងពាណិជ្ជកម្ម ឡើងដល់កំរិត ៤៤៥៧.៤ ពាន់លានរៀល ស្មើនឹង ១០៦៥លានដុល្លារ ស.រ.អ ដែលមានទំហំ ២៨.៣ %នៃតម្លៃនាំចេញ។ យោងតាមតួលេខ ឱនភាពជញ្ជីងពាណិជ្ជកម្ម តែងតែមានចំនួនធំ ក្នុងឆមាសទី១ ជាងឆមាសទី២ ។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. បញ្ហាសំខាន់ៗ នៃស្មារតីអង្គប្រជុំ

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗដូចខាងក្រោម៖*

១. **អតិផរណា៖** អត្រាថ្លៃទំនិញនៅព្រះរាជាណាចក្រកម្ពុជា ទទួលរងឥទ្ធិពលពីកត្តាសំខាន់ៗ ដូចជា៖

➢ ពំនឹងផ្អែកលើការនាំចូលពីប្រទេសជិតខាង ដែលធ្វើឲ្យកម្ពុជាងាយរងឥទ្ធិពលនៃបម្រែបម្រួលថ្លៃ និងអត្រាប្តូរប្រាក់ក្នុងប្រទេសទាំងនោះ

✓ នាឆ្នាំ២០១០នេះ សេដ្ឋកិច្ចវៀតណាមមានអតិផរណា ៩.២% និងថៃមានអតិផរណា ៣.០៣%[៣]

➢ និន្នាការកើនឡើងនៃតម្រូវការក្នុងស្រុកលើទំនិញ និងសេវាកម្ម

✓ តម្រូវការលើម្ហូបអាហារបេះតែកើនឡើងក្នុងសកលលោក

✓ ម្ហូបអាហារជាមុខទំនិញដែលមានការរួមចំណែកធំជាងគេលើអត្រាអតិផរណាកម្ពុជា

➢ គោលនយោបាយរបស់រាជរដ្ឋាភិបាលៈ ទាំងគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ

២. **ភាពប្រកួតប្រជែង៖** គោលនយោបាយបង្កើនភាពប្រកួតប្រជែង ជាមធ្យោបាយចាំបាច់សម្រាប់កម្ពុជា ក្នុង រយៈពេលមធ្យម និងវែងទៅមុខ។

➢ ប្រទេសវៀតណាម បានដាក់ផែនការក្លាយជាប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ ២០២០។ ការនេះតម្រូវឲ្យ វៀតណាមមានកំណែទំរង់គោលនយោបាយ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន។

✓ បច្ចុប្បន្ននេះ គោលនយោបាយបន្ទាបតម្លៃដុង ធ្វើឲ្យឧស្សាហកម្មនាំចេញវៀតណាម មានលក្ខណៈប្រកួតប្រជែងខ្ពស់ និងឧស្សាហកម្មកម្ពុជាអាចទទួលរងគ្រោះ។

➢ កម្ពុជាគួរពិនិត្យឡើងវិញ អំពីគោលនយោបាយរូបិយវត្ថុ ដុល្លារូបនីយកម្ម និងលទ្ធភាពឈានទៅរកការកែទម្រង់ ក្នុងគោលដៅកំណើនសេដ្ឋកិច្ច និងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន។

➢ គោលនយោបាយសារពើពន្ធ ក៏គួរត្រូវបានពិនិត្យឡើងវិញ ក្នុងគោលបំណងដោះស្រាយបញ្ហាឱនភាពថវិកាជាតិ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចជាតិ។

➢ ថ្លៃអគ្គិសនីមានកំរិតខ្ពស់ឥតឧបមាបើប្រៀបនឹងប្រទេសជិតខាង

៣. **សំណង់៖** វិស័យនេះមានការថយចុះយ៉ាងគំហុក

➢ វិនិយោគបរទេសក្នុងវិស័យនេះថយចុះ ៤៦%

➢ កម្មករប្រមាណ៤ម៉ឺននាក់ បាត់បង់ការងារ

➢ ដើម្បីលើកស្ទួយវិស័យនេះគួរមានលក្ខខ័ណ្ឌអំណោយផលដូចខាងក្រោម៖

✓ អត្រាការប្រាក់គប្បីត្រូវទាបជាងអត្រាបច្ចុប្បន្ន

✓ កាត់បន្ថយការិយាធិបតេយ្យ និងកែលំអរសេវាកម្ម

✓ ផ្តល់ការលើទឹកចិត្តមួយចំនួនចំពោះគម្រោងអាទិភាព

[៣] *General statistical office of Vietnam and National statistical office of Thailand*

## ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១០នេះ សូចនាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឱ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | បម្រែបម្រួល ធៀបនឹងឆ្នាំ ២០០៩ | ផ្សេងៗ |
|---|---|---|
| ១. ថ្លៃត្រីស្រស់ | +១០% | — |
| ២. ថ្លៃឧស្ម័ន | +៣០% | — |
| ៣. ថ្លៃប្រេងសាំង (ម៉ាស៊ូត) | +២២%(+២០%) | — |
| ៤. ចំណូលពន្ធ និងអាករគយ | +១៧% | ជាទូទៅចំណូលពន្ធ និងអាករគយ ក្នុងឆ្នាំ២០១០ ធ្វើបានលើសផែនការគ្រប់មុខចំណូល ដោយឡែក ខ្ទង់ចំណូលផ្សេងៗ មានការថយចុះ ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសជិតខាង |
| ៥. ចំណូលមិនមែនសារពើពន្ធ | +៤៩% | សម្បទានរ៉ែ និងការលក់អចលនកម្ម មានការកើនឡើងយ៉ាងខ្លាំង |
| ៦. ឧស្សាហកម្មធនតូច និងសិប្បកម្មបើកថ្មី | -១៤% | — |
| ៧. ឧស្សាហកម្មធនតូច និងសិប្បកម្មបន្ត | -៩៣% | — |
| ៨. សំណង់អនុញ្ញាត (ពាន់ម²) | -៩០% | មានការថយចុះខ្លាំងនូវសំណង់ ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ |
| ៩. អគ្គិសនីនាំចូលពីប្រទេសជិតខាង | +៩៧% | — |
| ១០. ការនាំចេញផលិតផលឈើកែច្នៃ | +៧០៩% | — |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០១/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំពិភាក្សាការងារ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ១០/០១/១១<br>ម៉ោង ០៨: ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យរំឭកខួបអនុស្សាវរីយ៍ នៃទិវាជ័យជំនះ ៧មករា-១៩៧៩-៧មករា-២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវេទិកាមុខសាលមហោស្រពខេត្តតាកែវ ។ |
| ៣ | ១៣/០១/១១<br>ម៉ោង ១០ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ចាន់ ស៊ុំ** អគ្គនាយករងពន្ធដារ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ១៨/០១/១១<br>ម៉ោង ១៧ : ០០ នាទី | ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធី បើកជាផ្លូវការវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០១១ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ។ |
| ៥ | ២០/០១/១១<br>ម៉ោង ០៩ : ៣០នាទី | ដឹកនាំកិច្ចប្រជុំវាយតម្លៃឯកសារដេញថ្លៃគម្រោងសាងសង់អគារលក់សំបុត្រពេលថ្ងៃនៃមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរណ៍ នៅខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ២០/០១/១១<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ៧ | ២១/០១/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ÷<br>១.សេចក្តីព្រាងច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>២.សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ០៣ឆ្នាំ រំកិល ២០១១-២០១៣។<br>៣.បញ្ហាផ្សេងៗ: សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីផ្ញើទៅ ស្ថាប័ននីតិប្បញ្ញត្តិលើ " ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន " ។ |
| ៨ | ២៤/០១/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការ ស្ពានមិត្តភាពកម្ពុជា-ចិន ព្រែកតាមាក់ ប្រវែង ១០៦៦ ម ក្រោមកម្ចីឥណទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅខាងលិចស្ពានមិត្តភាពកម្ពុជា-ចិន ព្រែកតាមាក់ ក្នុងភូមិកោះរកា ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ២៤/០១/១១<br>ម៉ោង ១៥: ០០នាទី | ដឹកនាំកិច្ចប្រជុំក្នុងពិធីចុះហត្ថលេខាលើការកែសម្រួលកំណត់ហេតុ និងអនុស្សរណៈយោគយល់គ្នារវាងអាជ្ញាធរអប្សរា និងស្ថានទូតឥណ្ឌា នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ១០ | ២៥/០១/១១<br>ម៉ោង ០៨:០០នាទី | អញ្ជើញទៅសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១១ | ២៥/០១/១១<br>ម៉ោង ១៧:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើគម្រោង " បោសសំអាតមីនដើម្បីអភិវឌ្ឍន៍ " ដំណាក់កាលទី២ រវាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាមួយគម្រោងអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ១២ | ២៦/០១/១១<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកវេទិកាជាតិ ស្ដីពីការជម្រុញចលនាភូមិមួយ ផលិតផលមួយ នៅកម្ពុជា គំរូខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋ មន្ត្រី នៅទីស្នាក់ការគណបក្សស្រុកគីរីវង់ ខេត្តតាកែវ។ |
| ១៣ | ២៦/០១/១១<br>ម៉ោង ១៦: ០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើ៖<br>១-សេចក្ដីព្រាងយុទ្ធសាស្ត្រជាតិគាំទ្រសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ។<br>២-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការគ្រប់គ្រងបុរី ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំ ជាមួយឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ១៤ | ២៧/០១/១១<br>ម៉ោង ០៩:០០នាទី | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈ រដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១-សេចក្ដីព្រាងយុទ្ធសាស្ត្រជាតិគាំទ្រសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ។<br>២-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការគ្រប់គ្រងបុរី ។<br>៣-បញ្ហាផ្សេងៗ ។ |
| ១៥ | ២៧/០១/១១<br>ម៉ោង ១៩:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀង នៅសណ្ឋាគារណាហ្គាវើល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង លោកជំទាវ។ |
| ១៦ | ៣១/០១/១១<br>ព្រឹក-ល្ងាច | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១-បូកសរុបការងារប្រចាំឆ្នាំ២០១០ និងលើកទិសដៅការងារឆ្នាំ២០១១<br>២-បញ្ហាផ្សេងៗ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម គឹម សយសាម៉ាឡែន
## អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១១

| លរ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១១/០១/១០ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតកាយរិទ្ធជាតិកម្ពុជា។<br>២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានកាយរឹទ្ធជាតិកម្ពុជា។<br>៣- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់សារធាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុកម្ម។<br>៤- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់។<br>៥- បញ្ហាផ្សេងៗ |
| ២ | ២៥/០១/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើគម្រោង " បោសសំអាតមីនដើម្បីអភិវឌ្ឍន៍ " ដំណាក់កាលទី២ រវាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាមួយគម្រោងអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២៧/០១/១១ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១-សេចក្តីព្រាង យុទ្ធសាស្ត្រជាតិគាំទ្រសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ។<br>២-សេចក្តីព្រាង អនុក្រឹត្យ ស្តីពីការគ្រប់គ្រងបុរី ។<br>៣-បញ្ហាផ្សេងៗ ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន
## អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១១

| លរ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១១/០១/១០ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតកាយរិទ្ធជាតិកម្ពុជា។<br>២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានកាយរឹទ្ធជាតិកម្ពុជា។<br>៣- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់សារធាតុគីមី ដែលទាក់ទងទៅនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុកម្ម។<br>៤- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់។<br>៥- បញ្ហាផ្សេងៗ |
| ២ | ២៥/០១/១១ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើគម្រោង " បោសសំអាតមីនដើម្បីអភិវឌ្ឍន៍ " ដំណាក់កាលទី២ រវាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាមួយគម្រោងអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២៧/០១/១១ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១-សេចក្តីព្រាង យុទ្ធសាស្ត្រជាតិគាំទ្រសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ។<br>២-សេចក្តីព្រាង អនុក្រឹត្យ ស្តីពីការគ្រប់គ្រងបុរី ។<br>៣-បញ្ហាផ្សេងៗ ។ |

## សកម្មភាពដទៃទៀតរបស់ សមាជិក-សមាជិកា
## នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/០១/១១ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំឆ្នាំ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |



រូបភាពក្នុងកិច្ចប្រជុំ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១០

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | Ék]tþm Km sysaNIþLn | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | Ék]tþm gan RþN | អគ្គលេខាធិការ ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | Ék]tþm mm saT | សមាជិកបម្រុង ក.ស.វ. |
| និពន្ធអក្ខបទ ៖ | Ék]tþm eGg rtþmÆ | អគ្គលេខាធិការរង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | elak sy vasn | ប្រធានការិយាល័យ ក.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | elak ehg sD3bR | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | elak mk Eta | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in